# «ខ្ញុំរំភើបចិត្តខ្លាំង ដែលបានឃើញស្នាមញញឹមពីឪពុកម្តាយទាំងសងខាង»

*ខ្ញុំរំភើបចិត្ត ដែលបានឃើញក្តីស្រមៃរបស់ពួកខ្ញុំបានជោគជ័យ ប៉ុន្តែខ្ញុំនៅបន្តធ្វើឱ្យបានជោគជ័យបន្តទៅមុខទៀត ដើម្បីសហគមន៍យើង បានសម្លេងច្រើន ឱ្យរាជរដ្ឋាភិបាលគាំទ្រយើងជាអ្នកស្រឡាញ់ភេទដូចគ្នា ឱ្យបានសមភាពច្បាប់អាពាហ៍ពិពាហ៍។*



ម៉ែរបស់ខ្ញុំ គាត់ធ្លាប់និយាយថាឱ្យខ្ញុំរៀបការទៅទាន់ម៉ែនៅរស់ ហើយខ្ញុំចាំពាក្យនេះនៅក្នុងចិត្តរហូតមក។ តាំងពីចាប់ដៃគ្នាអស់រយៈកាល៥ឆ្នាំមកនេះ ខ្ញុំទាំងពីរនាក់ប្តីប្រពន្ធ បានប្តេជ្ញាចិត្តខិតខំប្រឹងប្រែង ដើម្បីបានរៀបការទាន់ម៉ែឪរបស់យើងនៅមានព្រះជន្ម។ ពួកខ្ញុំ រៀបចំកម្មវិធីអាពាហ៍ពិពាហ៍នេះ ផ្តួបជាមួយនឹងកម្មវិធីឡើងផ្ទះថ្មី។ ខ្ញុំរំភើបចិត្តមែនទែន ដែលក្តីស្រមៃរបស់ខ្ញុំបានជោគជ័យ។ នៅថ្ងៃកម្មវិធីអាពាហ៍ពិពាហ៍របស់ខ្ញុំ ខ្ញុំបានឃើញស្នាមញញឹមពីឪពុក ម្តាយ សាច់ញាតិបងប្អូនទាំងសងខាង លោកមេភូមិ មានបងប្អូនសហគមន៍យើង គាត់មកចូលរួមកុះករច្រើនមែនទែន ហ្នឹងហើយ គឺភាពកក់ក្តៅរបស់ខ្ញុំទាំងពីរនាក់ ហើយវត្តមានរបស់ពួកគាត់ទាំងអស់គ្នា ធ្វើឱ្យពួកខ្ញុំ មានអារម្មណ៍ថាទទួលបានការស្រឡាញ់ និងការគាំទ្រយ៉ាងខ្លាំងពីគាត់។ ខ្ញុំចាប់អារម្មណ៍ថាឪពុកម្តាយទាំងសងខាងគាត់សប្បាយចិត្តណាស់ ជាពិសេសពេលខ្ញុំជូនផ្កាស្លាជូនគាត់ គឺញញឹមរហូត។ លើសពីនេះ ខ្ញុំបានទទួលក្តីរំភើបមួយទៀត ពីបងប្រុសរបស់ខ្ញុំ ដែលពីមុនគាត់មិនទទួលយកខ្ញុំទេ។ តែថ្ងៃកម្មវិធីការរបស់ខ្ញុំ គាត់បានមកចូលរួមហើយគាត់សរសើរការខិតខំប្រឹងប្រែងរបស់ខ្ញុំទាំងពីរនាក់។ ខ្ញុំរំភើបចិត្តណាស់! ឥលូវខ្ញុំបានជោគជ័យហើយ ប៉ុន្តែខ្ញុំនៅបន្តធ្វើឱ្យបានជោគជ័យបន្តទៅមុខទៀត នៅពុះពារជាមួយប៉ាយន់ ដើម្បីសហគមន៍យើងបានសម្លេងច្រើន ឱ្យរាជរដ្ឋាភិបាលគាំទ្រយើងជាអ្នកស្រឡាញ់ភេទដូចគ្នា ដើម្បីឱ្យបានសមភាពច្បាប់អាពាហ៍ពិពាហ៍។




##